# ដៃជាជំនួយ ដៃជួយសង្គ្រោះ

*អែលឌើរ ខូល អ័យយ៉ាល់*
*នៃពួកចិតសិបនាក់*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឱកាស ដើម្បី និយាយនៅក្នុងសន្និសីទនេះ។ ខ្ញុំមានអំណរគុណចំពោះប្រធាន ថូម៉ាស អេស ម៉នសុន ហើយខ្ញុំសូមធ្វើទីបន្ទាល់ថា លោកគឺជាព្យាការីនៃព្រះអម្ចាស់ដ៏មានព្រះជន្មរស់។ ខ្ញុំមានការកោតសរសើរយ៉ាងខ្លាំងចំពោះគំរូដ៏អស្ចារ្យរបស់ប្រធាន ម៉នសុន ដែលបានចំណាយជីវិតរបស់លោក ប្រើប្រាស់ដៃរបស់លោក ដើម្បីជួយ និងសង្គ្រោះដល់អ្នកដទៃទៀត។

យើងរស់នៅក្នុងជំនាន់មួយ ដែលមនុស្សជាច្រើនបានជួបប្រទះនឹងវិបត្តិ ហើយត្រូវការជំនួយ ដោយសារតែរងឥទ្ធិពលបំផ្លិចបំផ្លាញមកពីការរញ្ជួយដី រលកយក្សស៊ូណាមិ ខ្យល់ព្យុះ និងគ្រោះថ្នាក់ធម្មជាតិផ្សេងៗទៀត។ សាសនាចក្រ បានជួយដល់មនុស្សទាំងនេះ តាមរយៈជំនួយមនុស្សធម៌។ សមាជិកស្មោះត្រង់ក្នុងសាសនាចក្របានផ្តល់ដង្វាយតមអាហារដោយចិត្តសប្បុរសជារៀងរាល់ខែ ហើយធ្វើការបំរើដោយសេចក្តីស្រឡាញ់។ ពួកគេពិតជាបានជួយ តាមរបៀបរបស់ព្រះអម្ចាស់។ ពួកគេបានធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដើម្បី «នឹកចាំក្នុងគ្រប់ការណ៍ទាំងអស់ ពីមនុស្សទាល់ក្រ និងមនុស្សកំសត់ទុរគត់ និងពីមនុស្សឈឺ និងមនុស្សមានទុក្ខវេទនា ត្បិតអ្នកណាដែលមិនធ្វើការទាំងនេះទេ អ្នកនោះឈ្មោះថាមិនមែនជាសិស្សរបស់យើងឡើយ» (គ. និង ស. 52:40)។

នៅថ្ងៃនេះ ខ្ញុំចង់ផ្តោតទៅលើ ដៃជាជំនួយ និងដៃជួយសង្គ្រោះខាងព្រលឹងវិញ្ញាណ។ កិច្ចការ និងសិរីល្អរបស់ព្រះអម្ចាស់ គឺពិតជាដើម្បី «នាំឱ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស» (ម៉ូសេ 1:39)។ មនុស្សជាច្រើនដែលនៅជុំវិញយើង ត្រូវការជំនួយខាងវិញ្ញាណ។ នៅពេលយើងផ្តល់ដៃជួយសង្គ្រោះដល់សមាជិកមិនសូវសកម្ម គ្រួសារដែលមានសមាជិកតែម្នាក់ និងអ្នកទាំងឡាយដែលពុំមានជំនឿដូចយើង នោះយើងអញ្ជើញមនុស្សទាំងអស់ឱ្យ «មករកព្រះគ្រីស្ទ»។ 1

ក្នុងនាមជាអ្នកផ្លាស់ប្រែចិត្តជឿថ្មីក្នុងសាសនាចក្រ ខ្ញុំទទួលបទពិសោធន៍ការជួយសង្គ្រោះខាងវិញ្ញាណ តាមរយៈដៃជួយសង្គ្រោះរបស់សមាជិកស្មោះត្រង់ក្នុងសាសនាចក្រ។ ខ្ញុំធំឡើងនៅក្នុងទីក្រុង ម៉ាជូម៉ូតូ ប្រទេសជប៉ុន នៅជិតកន្លែងដែលប្រារព្ធធ្វើកីឡាអូឡាំពិច ណាហ្គាណូ នារដូវរងារ។ ទីក្រុងរបស់ខ្ញុំមើលទៅ ស្រដៀងគ្នានឹង ទីក្រុងសលត៍ លេកណាស់ មានជ្រលងភ្នំនៅព័ទ្ធជុំវិញយ៉ាងស្រស់ស្អាត។ នៅពេលខ្ញុំមានអាយុ 17 ឆ្នាំ ខ្ញុំបានជួបនឹងអ្នកផ្សព្វផ្សាយសាសនាជនជាតិអាមេរិកពីរនាក់ ឈ្មោះអែលឌើរ ខាធី និង អែលឌើរ ហាយ៉ាឈី។ ទោះជាយើងមានអាយុខុសគ្នាគ្រាន់តែពីរបីឆ្នាំក៏ដោយ តែពួកអែលឌើរមានអ្វីមួយដ៏អស្ចារ្យ ដែលខ្ញុំមិនធ្លាប់ បានទទួលអារម្មណ៍ពីមុនមកទេ។ ពួកគេឧស្សាហ៍ព្យាយាម ពោរពេញដោយ

ភាពរីករាយ សេចក្តីស្រឡាញ់ និងពន្លឺ។ ខ្ញុំកោតសរសើរយ៉ាងខ្លាំងចំពោះគុណសម្បត្តិរបស់ពួកគេ ហើយចង់ក្លាយខ្លួនដូចជាពួកគេដែរ។ ខ្ញុំបានស្តាប់សារលិខិតរបស់ពួកគេ ហើយបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក។ ឪពុកម្តាយខ្ញុំ ដែលជាអ្នកកាន់សាសនាព្រះពុទ្ធ បានជំទាស់នឹងពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំយ៉ាងខ្លាំង។ តាមរយៈជំនួយរបស់អ្នកផ្សព្វផ្សាយសាសនា និងព្រះអម្ចាស់ នោះខ្ញុំបានទទួលការអនុញ្ញាត ហើយត្រូវបានទទួលបុណ្យជ្រមុជទឹក ប្រកបដោយអព្ភូតហេតុ។

នៅឆ្នាំបន្ទាប់ ខ្ញុំចូលរៀនសាកលវិទ្យាល័យនៅយ៉ូកូហាម៉ា។ ការរស់នៅតែម្នាក់ឯង ឆ្ងាយពីទីក្រុងរបស់ខ្ញុំ និងឆ្ងាយពីមនុស្សដែលខ្ញុំស្គាល់ នោះខ្ញុំបានក្លាយទៅជាមនុស្សឯកកោ ហើយវង្វេងចេញពីសាសនាចក្រ។ នៅថ្ងៃមួយ ខ្ញុំទទួលបានកាតមួយមកពីសមាជិកសាសនាចក្រនៅឯផ្ទះ។ នាងបានសរសេរថា នាងបានឮថាខ្ញុំមិនបានចូលរួម ការប្រជុំសាសនាចក្រទៀតទេ នាងបានដកស្រង់ខគម្ពីរមួយ ហើយបានអញ្ជើញខ្ញុំឱ្យត្រឡប់មកសាសនាចក្រវិញ។ ខ្ញុំបានរំជួលចិត្តដោយពាក្យសំដីនៃបទគម្ពីរនោះ។ រឿងនេះបានជួយខ្ញុំឱ្យដឹងច្បាស់ថា ប្រហែលជាខ្ញុំបានបាត់បង់អ្វីមួយ សំខាន់ ហើយខ្ញុំបានពិចារណា និងស្មុគស្មាញអស់រយៈពេលជាច្រើនថ្ងៃ។ រឿងនេះបានបណ្តាលឱ្យខ្ញុំចងចាំនូវការសន្យាមួយរបស់ពួកអ្នកផ្សព្វផ្សាយសាសនាមានចំពោះខ្ញុំថា «បើសិនជាអ្នកអានព្រះគម្ពីរមរមន ហើយសួរដោយក្លៀវក្លានៅក្នុងការអធិស្ឋាន បើសិនជាការសន្យាដែលមាននៅក្នុងគម្ពីរម៉ូរ៉ូណៃគឺជាការពិត នោះអ្នកនឹងដឹងសេចក្តីពិត តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ»។ 2

ខ្ញុំបានដឹងច្បាស់ថា ខ្ញុំមិនបានអធិស្ឋានដោយអស់ពីដួងចិត្តរបស់ខ្ញុំទេ រួចក៏បានសម្រេចចិត្តធ្វើដូច្នោះ។ នៅព្រឹកមួយ ខ្ញុំបានក្រោកឡើងពីព្រលឹម លុតជង្គង់នៅក្នុងផ្ទះតូចរបស់ខ្ញុំ ហើយបានអធិស្ឋានដោយអស់ពីចិត្ត។ ខ្ញុំបានភ្ញាក់ផ្អើល ចំពោះការបញ្ជាក់មកពីព្រះវិញ្ញាណបរិសុទ្ធ ចាក់ស្រោចមកលើខ្ញុំ ដូចដែលបានសន្យា។ ដួងចិត្តរបស់ខ្ញុំត្រូវបានដុត រាងកាយរបស់ខ្ញុំញ័រចំប្រប់ ហើយខ្ញុំពោរពេញទៅដោយក្តីអំណរ។ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ខ្ញុំបានដឹងថា ព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ មានព្រះជន្មរស់ ហើយថា ពួកទ្រង់ពិតជាបានយាងចេញមកជួបយ៉ូសែប ស៊្មីធ។ ខ្ញុំបានធ្វើការប្តេជ្ញាចិត្តមួយ នៅក្នុងដួងចិត្តរបស់ខ្ញុំថា ត្រូវតែប្រែចិត្ត ហើយដើរតាមព្រះយេស៊ូវគ្រីស្ទដោយស្មោះត្រង់ អស់មួយជីវិតរបស់ខ្ញុំ។

បទពិសោធន៍ខាងវិញ្ញាណនេះ បានផ្លាស់ប្តូរជីវិតរបស់ខ្ញុំទាំងស្រុង! ខ្ញុំបានសម្រេចចិត្តបំរើបេសកកម្ម ដែលផុសចេញមកពីការដឹងគុណចំពោះព្រះអម្ចាស់ និងចំពោះសមាជិកសាសនាចក្រ ដែលបានជួយសង្គ្រោះខ្ញុំ។ បន្ទាប់ពីបេសកកម្មរបស់ខ្ញុំ ខ្ញុំបានផ្សាភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធជាមួយនឹងនារីដ៏ល្អម្នាក់ ហើយយើងត្រូវបានប្រទានពរឱ្យមានកូនចំនួនបួននាក់។ មិនមែនជាភាពចៃដន្យទេ នារីម្នាក់នេះ គឺជានារីដែលបានជួយសង្គ្រោះខ្ញុំ តាមរយៈការផ្ញើរកាត ទៅកាន់ផ្ទះឯកកោនៅទីក្រុងយ៉ូកូហាម៉ា អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅនោះ។ ត្រឡប់ទៅទំនុកដំកើង «ទូលបង្គំបានវង្វេងដូចជាចៀមបាត់បង់ សូមដេញរកអ្នកបំរើ

ទ្រង់ផង ត្បិតទូលបង្គំមិនភ្លេចសេចក្ដីបង្គាប់របស់ទ្រង់ឡើយ» (ទំនុកដំកើង 119:176)។ ខ្ញុំនៅតែមានអំណរគុណចំពោះសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ និងជំនួយរបស់សមាជិកនៃសាសនាចក្រនេះ ដែលបានអញ្ជើញខ្ញុំឱ្យ «មករកព្រះគ្រីស្ទ» ជាថ្មីម្ដងទៀត។ 3

ខ្ញុំដឹងថា អ្នករាល់គ្នាជាច្រើន បានផ្ដល់ឱ្យនូវដៃនៃក្ដីស្រឡាញ់ និងការសង្គ្រោះជារៀងរាល់ថ្ងៃដោយសម្ងាត់។ រឿងនេះរួមមានទាំងបងប្អូនស្ត្រីសមាគមសង្គ្រោះស្មោះត្រង់មួយរូប ដែលមិនមែនយកចិត្តទុកដាក់តែចំពោះបងប្អូនស្ត្រី ដែលគាត់ត្រូវបានចាត់ឱ្យទៅបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែគាត់ទៅរកបងប្អូនស្ត្រីដែលឈឺ ឬត្រូវការជំនួយដោយប្រការណាផ្សេងទៀតផងដែរ។ គាត់សួរសុខទុកជាញឹកញាប់ ហើយបានសួរសុខទុក្ខ អស់រយៈពេលជាច្រើនឆ្នាំ គាត់បានពង្រឹងសេចក្ដីជំនឿរបស់មនុស្សជាច្រើន។ ខ្ញុំបានគិតអំពីបីស្សពមួយរូប ដែលជារឿយៗបានសួរសុខទុក្ខដល់ស្ត្រីមេម៉ាយ និងពោះម៉ាយ នៅក្នុងវួដរបស់គាត់។ គំរូនៃការជួយនេះ បានបន្តអស់រយៈពេលជាច្រើនឆ្នាំ បន្ទាប់ពីការដោះលែងពីដំណែងរបស់គាត់។

ខ្ញុំស្គាល់អ្នកកាន់បព្វជិតភាពម្នាក់ ដែលចំណាយពេលជាមួយនឹងយុវជនម្នាក់ ដែលបានបាត់បង់ឪពុករបស់គាត់។ គាត់ចូលរួមនៅក្នុងសកម្មភាពជាច្រើនជាមួយនឹងយុវជននោះ បង្រៀនដល់គាត់អំពីដំណឹងល្អ ហើយផ្ដល់ដំបូន្មាន ដូចជាឪពុករបស់គាត់ផងដែរ។ គ្រួសារផ្សេងទៀត រីករាយនៅក្នុងការចែកចាយដំណឹងល្អ។ ឪពុកម្ដាយ និងកូនម្នាក់ៗ ថ្លែងទីបន្ទាល់អំពីដំណឹងល្អទៅដល់មនុស្សទាំងឡាយដែលនៅជុំវិញពួកគេ ហើយមានមនុស្សជាច្រើនស្រឡាញ់រាប់អាន។

ជាចំណែកនៅក្នុងសកម្មភាពអង្គការបឋមសិក្សា ចៅស្រីអាយុប្រាំឆ្នាំរបស់ខ្ញុំ បានដាក់គ្រាប់ពោតលីងនៅក្នុងដបកែវដ៏ធំមួយ រាល់ពេលដែលនាងបានធ្វើទង្វើរល្អ។ នាងបានច្រៀងចំរៀងកុមារបទនេះខ្លាំងៗ នៅពេលនាងស្វែងរករឿងល្អ ដើម្បីធ្វើជារៀងរាល់ថ្ងៃ «ធ្វើតាមព្យាការី ធ្វើតាមព្យាការី ធ្វើតាមព្យាការី លោកស្គាល់ផ្លូវត្រូវ!» 4

ខ្ញុំគ្មានពេលនឹងប្រាប់ដល់អ្នករាល់គ្នាអំពីរឿងល្អៗទាំងអស់ ដែលខ្ញុំមើលឃើញសមាជិកក្នុងសាសនាចក្រធ្វើនោះទេ។ ពួកគាត់ធ្វើតាមដំបូន្មានរបស់ព្យាការី ពុំមែនដោយសារកាតព្វកិច្ច ឬការទទួលខុសត្រូវនោះទេ ប៉ុន្តែដោយស្មគ្រ័ចិត្ត ដោយសម្ងាត់ និងដោយក្ដីអំណរ។

នៅពេលខ្លះ យើងមានអារម្មណ៍ថា យើងទន់ខ្សោយ និងខ្វះកម្លាំងដើម្បីជួយសង្គ្រោះអ្នកដទៃ ប៉ុន្តែព្រះអម្ចាស់រំឭកដល់យើងថា «យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ» (ម៉ាថាយ 25:40)។

ខ្ញុំសូមបញ្ចប់ជាមួយនឹងពាក្យដកស្រង់មួយ ដោយប្រធានថូម៉ាស អេស ម៉នសុនថា៖ «បងប្អូនប្រុសស្រី

របស់ខ្ញុំ យើងរុំព័ទ្ធទៅដោយពួកអ្នកដែលត្រូវការ ការយកចិត្តទុកដាក់ ការលើកទឹកចិត្ត ការគាំទ្រ ការលួងលោម និងសណ្ដានចិត្តរបស់យើង---មិនថាពួកគេជាសមាជិកគ្រួសារ ជាមិត្តភក្ដិ ជាអ្នកស្គាល់គ្នា ឬជាមនុស្សចម្លែក នោះឡើយ។ យើងគឺជាព្រះពាហុរបស់ព្រះអម្ចាស់នៅលើផែនដីនេះ ដែលត្រូវបានបញ្ជាឱ្យបំរើ និងលើកស្ទួយដល់កូនចៅរបស់ ទ្រង់។ ទ្រង់ពឹងផ្អែកទៅលើយើងម្នាក់ៗ»។ 5

សូមឱ្យយើងធ្វើតាមដំបូន្មាន និងគំរូរបស់ព្យាការី ហើយស្វែងរកអ្នកដែលខ្វះខាតជារៀងរាល់ថ្ងៃ ដើម្បីយើងអាចធ្វើជាព្រះហស្តរបស់ព្រះអម្ចាស់ នៅក្នុងការជួយ និងការសង្គ្រោះដល់កូនចៅរបស់ទ្រង់ ខ្ញុំសូមអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. សូមមើល ប្រកាសដំណឹងល្អរបស់យើង (ឆ្នាំ 2004) ទំព័រ 1។
2. សូមមើល ម៉ូរ៉ូណៃ 10:4--5។
3. សូមមើល ម៉ាថាយ 11:28។
4. «Follow the Prophet» Children's Songbook (ឆ្នាំ 1989) ទំព័រ 110។
5. Thomas S. Monson {What have I Done for Someone Today?} Ensign ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 84។